ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

**សុន្ទរកថាបើក**
**លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១**
**និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៥ របស់ធនាគារជាតិនៃកម្ពុជា**
ថ្ងៃចន្ទ ៣កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥
នៅធនាគារជាតិនៃកម្ពុជាអគារសែនសុខ រាជធានីភ្នំពេញ

សូមគោរព៖

- គណៈអធិបតី

- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!

មុននឹងចាប់ផ្តើម តាងនាមឱ្យធនាគារជាតិនៃកម្ពុជានិងរូបខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងការសោកស្តាយ និងចូលរួមចែករំលែកទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះការបាត់បង់អាយុជីវិតរបស់កងទ័ពកម្ពុជាដ៏ក្លាហាននិងប្រជាពលរដ្ឋស្លូតត្រង់ នៅក្នុងការវាយប្រហារពីកងទ័ពថៃមកលើទឹកដីកម្ពុជា។ យើងទាំងអស់គ្នាជឿជាក់ និងគាំទ្រទាំងស្រុងចំពោះការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងសូមផ្តល់កម្លាំងចិត្តដល់វីរកងទ័ពនៅជួរមុខរបស់យើងក្នុងបុព្វហេតុការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិកម្ពុជា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

នាឆមាសទី១ ឆ្នាំ២០២៥ នេះ សេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងភាពមិនប្រាកដប្រជាកាន់តែខ្លាំង ដែលក្នុងនោះរួមមាន៖ ១/-ការប្រកាសពន្ធគយបដិការរបស់សហរដ្ឋអាមេរិក ដែលបានធ្វើឱ្យរង្គោះរង្គើដល់គោលការណ៍ពហុភាគីនិយម ក៏ដូចជាសាកលភាវូបនីយកម្មដែលកន្លងមកត្រូវបានចាត់ទុកថាជាកម្លាំងចលករដ៏សំខាន់មួយ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចពិភពលោកចាប់តាំងពីក្រោយសង្គ្រាមលោកលើកទី២ ជាពិសេសចំពោះប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍ និង ២/-ការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ជម្លោះ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ប្រដាប់អាវុធនៅមជ្ឈិមបូព៌ា ព្រមទាំងភាពតានតឹងភូមិសាស្ត្រនយោបាយនៅអាស៊ី បាននាំឱ្យមានអស្ថិរភាពសេដ្ឋកិច្ចនិងសង្គម។

ភាពមិនច្បាស់លាស់និងផលប៉ះពាល់នៃបញ្ហាខាងលើ បានធ្វើឱ្យកំណើនសេដ្ឋកិច្ចពិភពលោកថយល្បឿន ហើយប្រឈមនឹងហានិភ័យថមថយថែមទៀតនាឆ្នាំ២០២៥ នេះ និងឆ្នាំ២០២៦ ខាងមុខ។ ស្ថានភាពនេះ ពិតជាបានផ្តល់ផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា ដែលជាប្រទេសតូច បើកចំហ និងពឹងផ្អែកលើវិស័យខាងក្រៅ ជាពិសេស ការនាំចេញ ការវិនិយោគ និងទេសចរណ៍។

ទោះយ៉ាងណា ក្នុងរយៈពេល ៦ខែកន្លងមកនេះ កម្ពុជានៅសម្រេចបានកំណើន ៥,៩% ដែលត្រូវបានគាំទ្រជាចម្បងដោយកំណើននៃការនាំចេញផលិតផលកម្មន្តសាល វិស័យទេសចរណ៍ និងកសិកម្ម ក្នុងបរិការណ៍ដែលអត្រាអតិផរណាស្ថិតក្នុងកម្រិតទាបអាចគ្រប់គ្រងបាន និងស្ថិរភាពល្អប្រសើរនៃអត្រាប្តូរប្រាក់។ អត្រាអតិផរណាជាមធ្យមមានកម្រិត ៣,៥% ដោយបានថយចុះយ៉ាងឆាប់រហ័សពី ៦% ក្នុងខែមករា មកនៅត្រឹម ១,៦% នាខែមិថុនា។ លទ្ធផលនេះសម្រេចបាន ស្ថិតក្នុងរយៈពេលដែលពន្ធតយបដិការរបស់សហរដ្ឋអាមេរិកមិនទាន់ត្រូវបានអនុវត្តនៅឡើយរហូតដល់ដើមខែសីហាខាងមុខ ដែលធ្វើឱ្យមានការបង្កើនការបញ្ជាទិញខ្ពស់ពីសហរដ្ឋអាមេរិកលើផលិតផលកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០២៥ នេះ។

ខ្ញុំក៏ចង់រំលេចផងដែរថា កន្លងមកមានការព្រួយបារម្ភពីការកើនឡើងថ្លៃទំនិញប្រើប្រាស់ក្រោយពីការបិទច្រកព្រំដែនកម្ពុជា-ថៃ ជាពិសេសទៅលើប្រេងឥន្ធនៈ បន្លែ និងផ្លែឈើ។ ធនាគារជាតិនៃកម្ពុជាបានតាមដានការប្រែប្រួលថ្លៃយ៉ាងយកចិត្តទុកដាក់ ហើយបានពិនិត្យឃើញថា ទំនិញនាំចូលពីប្រទេសថៃស្ទើរតែទាំងអស់ គឺជាទំនិញដែលអាចជំនួសបានដោយផលិតផលក្នុងស្រុកនិងការនាំចូលពីប្រទេសផ្សេងៗ ដែលបន្តរក្សាបានស្ថិរភាពថ្លៃទំនិញប្រើប្រាស់ ពោលគឺមានតែនៅតាមតំបន់ជាប់ព្រំដែនកម្ពុជា-ថៃប៉ុណ្ណោះ ដែលថ្លៃទំនិញថៃមួយចំនួនតូចបានកើនឡើង ប៉ុន្តែក៏បានថយចុះមកវិញហើយដែរ ដោយសារការប្រើប្រាស់ទំនិញជំនួស។

ជារួម ការគ្រប់គ្រងបានស្ថិរភាពថ្លៃនេះ គឺដោយសារគោលនយោបាយបុរេសកម្មរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រផលិតផលក្នុងស្រុក និងការធ្វើពិពិធកម្មទំនិញនាំចូល។ ជាមួយគ្នានេះ ការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ ជាមួយនឹងនិន្នាការឡើងថ្លៃធៀបនឹង

បណ្តាឆ្នាំមុនៗ បានជួយបន្ថយសម្ពាធអតិផរណាផងដែរ។ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកជាមធ្យមមានកម្រិត ៤.០១១ រៀលក្នុង ១ដុល្លារអាមេរិក នាឆមាសទី១នេះ ធៀបនឹងឆ្នាំមុន ដែលមានកម្រិត ៤.០៧៥ រៀល ហើយមុនវិបត្តិកូវីដ-១៩ មានកម្រិត ៤.០៣៩ រៀល ក្នុង ១ដុល្លារអាមេរិក។ ស្ថិរភាពអត្រាប្តូរប្រាក់ល្អប្រសើរ គួបផ្សំនឹងការបន្តសម្រេចបានកំណើនសេដ្ឋកិច្ច បានបង្កលក្ខណៈអំណោយផលដល់ធនាគារជាតិនៃកម្ពុជាក្នុងការគរពូនទុនបម្រុងអន្តរជាតិឱ្យកើនឡើង ១០,៤% ធៀបនឹងចុងឆ្នាំ២០២៤ ដល់ ២៤,៨ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹង ៧,៥ ខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់ ដែលខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍ។

ជាមួយនឹងការរួមចំណែករក្សាបានបេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា ប្រព័ន្ធធនាគារបានរួមចំណែកពង្រឹងជំនឿទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជា និងទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ដែលកំពុងប្រឈមនឹងភាពមិនច្បាស់លាស់ពីកត្តាខាងក្រៅ និងបញ្ហាជក់សល់មួយចំនួននៅក្នុងស្រុក។ ជាក់ស្តែង ប្រព័ន្ធធនាគារកម្ពុជាបន្តទទួលបានកំណើនទ្រព្យសកម្មក្នុងអត្រា ៧,៣% និងកំណើនប្រាក់បញ្ញើ ១៤,៥%។ ជាការពិត ថ្វីបើក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ សេដ្ឋកិច្ចកម្ពុជាបានទទួលរងឥទ្ធិពលពីកត្តាខាងក្រៅជាបន្តបន្ទាប់ក្តី ក៏ប្រព័ន្ធធនាគារនៅតែរក្សាបានភាពធន់ ដែលអាចឆ្លុះបញ្ចាំងតាមរយៈភាពរឹងមាំនៃដើមទុន និងកម្រិតខ្ពស់នៃសន្ទនីយភាព។ គួរកត់សម្គាល់ថា ឥណទានមានកំណើនទាបត្រឹម ២,៩% ដោយសារគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការប្រុងប្រយ័ត្នក្នុងការផ្តល់ឥណទានក្នុងស្ថានភាពមិនប្រាកដប្រជា ស្របពេលដែលតម្រូវការឥណទានបានថមថយ ដោយសារវិស័យសេដ្ឋកិច្ចមួយចំនួននៅមិនទាន់ងើបឡើងបានពេញលេញនៅឡើយ ជាពិសេសវិស័យអចលនទ្រព្យ សំណង់ និងទេសចរណ៍។ ដើម្បីពង្រឹងការការពារហានិភ័យឥណទានជាយថាហេតុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបង្កើនការធ្វើសំវិធានធនក្នុងកម្រិតសមស្របតាមបទប្បញ្ញត្តិ។ ផលវិបាកជក់សល់ពីវិបត្តិកូវីដ-១៩ និងភាពមិនទាន់ងើបឡើងទាំងស្រុងនៃវិស័យសេដ្ឋកិច្ចមួយចំនួន គួបផ្សំនឹងការកើនឡើងនៃសំវិធានធននិងកំណើនទាបនៃឥណទានបាននាំឱ្យអនុបាតឥណទានមិនដំណើរការកើនឡើងដល់ ៨,៣% នាឆមាសទី១នេះ។ ទោះយ៉ាងនេះក្តី ប្រសិនបើមិនរាប់បញ្ចូលការធ្វើសំវិធានធនក្នុងការគណនា អនុបាតឥណទានមិនដំណើរការសុទ្ធមានកម្រិតត្រឹម ២,៧% ប៉ុណ្ណោះ។

លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តរៀបចំឥណទានឡើងវិញ ជូនដល់អតិថិជន ដែលបច្ចុប្បន្នមានចំនួន ៣,៧ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៦,៥% នៃឥណទានសរុបសម្រាប់គណនីចំនួន ១៧៨,៩ ពាន់។ ដើម្បីគាំទ្រវិធានការនេះឱ្យប្រព្រឹត្តទៅដោយពិលាសវិធានការអនុគ្រោះបទប្បញ្ញត្តិមួយចំនួនត្រូវបានអនុវត្ត ដូចជាការរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិត ៧% និងការអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើរវេសិនត្រឹម ១,២៥% ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសាច់ប្រាក់គ្រប់គ្រាន់ ក្នុងការរៀបចំឥណទានឡើងវិញតាមការចាំបាច់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ស្របតាមបរិវត្តកម្មឌីជីថល និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឱ្យកាន់តែទំនើប សម្បូរបែប និងសុវត្ថិភាព ទាំងការទូទាត់ឆ្លងគ្រឹះស្ថានក្នុងស្រុក និងការទូទាត់ឆ្លងដែន ដែលបានគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងសមាហរណកម្មប្រព័ន្ធទូទាត់សងប្រាក់ទៅក្នុងតំបន់និងអន្តរជាតិ។ នាឆមាសទី១នេះ សេវាទូទាត់សងប្រាក់ឌីជីថលជារៀលបានកើនដល់ ២៣៥,៤ ទ្រីលានរៀល និងជាដុល្លារអាមេរិកបានកើនដល់ ១៧៧,៥ ប៊ីលានដុល្លារអាមេរិក។ បន្ថែមលើនេះ តាមរយៈប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបានតភ្ជាប់ការទូទាត់ឆ្លងដែនតាមយន្តអរកូដជាមួយប្រទេសថៃ ឡាវ វៀតណាម ម៉ាឡេស៊ី កូរ៉េខាងត្បូង និងជប៉ុន និងក្រុមហ៊ុន UnionPay និង Alipay។

ខ្ញុំសូមរំលេចផងដែរថា ការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយចំនួនអ្នកដាក់ប្រាក់បញ្ញើបានកើនឡើង ១៣,៩% ដល់ ១៥,៧ លាននាក់ ហើយចំនួនអ្នកប្រើប្រាស់សេវាឥណទានបានកើន ២២,៧% ដល់ ៤,៥ លាននាក់។ ទន្ទឹមនេះ ចំនួនពាណិជ្ជករចុះឈ្មោះប្រើប្រាស់ខេអេចយន្តអរកូត បានកើនដល់ ៤,៩ លានគណនី ដែលបង្ហាញពីនិន្នាការនៃការងាកមកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ កាន់តែច្រើនជាងមុនរបស់អាជីវកម្មខ្នាតតូចនិងមធ្យម និងនៅតាមទីជនបទ។

ទន្ទឹមនឹងការកើនឡើងនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ បញ្ហាឆបោកតាមប្រព័ន្ធអនឡាញក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ នៅលើពិភពលោក នៅក្នុងយុគសម័យនៃការរីកចម្រើននៃបច្ចេកវិទ្យា ដែលបាននិងកំពុងបណ្តាលឱ្យមាន

ការខាតបង់យ៉ាងធ្ងន់ធ្ងរ។ ឆ្លើយតបនឹងបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធនាការនិងវិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីលុបបំបាត់បណ្ដាញនិងក្រុមឆបោកតាមប្រព័ន្ធអនឡាញ (online scam) ដែលឆ្លៀតឱកាសយកទឹកដីកម្ពុជាធ្វើជាទីតាំងក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ជាប្រចាំនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន ហើយបានសហការយ៉ាងសកម្មជាមួយភាគីពាក់ព័ន្ធដើម្បីប្រយុទ្ធប្រឆាំងនឹងការឆបោកអនឡាញ សំដៅការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ក្រៅពីនេះ ការផ្សព្វផ្សាយពីចំណេះដឹងផ្នែកឌីជីថលនិងហានិភ័យ ដែលអាចកើតមានពីការប្រើប្រាស់ប្រព័ន្ធឌីជីថល ដូចជាការបន្លំឃ្យូអរកូត ការលួចអត្តសញ្ញាណ លេខគណនី ឬព័ត៌មានឯកជនសំខាន់ៗ និងវិធីផ្សេងៗដែលជនទុច្ចរិតប្រើប្រាស់ក្នុងការឆបោកតាមប្រព័ន្ធអនឡាញនាពេលកន្លងមក ដើម្បីលើកកម្ពស់ការប្រុងប្រយ័ត្នរបស់សាធារណជន។ សេចក្ដីណែនាំ ស្ដីពីការគ្រប់គ្រងហានិភ័យផ្នែកបច្ចេកវិទ្យាស្របតាមស្តង់ដាអន្តរជាតិក៏ត្រូវបានដាក់ចេញ សំដៅពង្រឹងការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យានៅក្នុងប្រព័ន្ធធនាគារឱ្យកាន់តែរឹងមាំថែមទៀតផងដែរ។

ម្យ៉ាងទៀត អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានបន្តខិតខំប្រឹងប្រែងអនុវត្តការងារជាប្រចាំ ដើម្បីបង្កើនជំនឿទុកចិត្តពីសាធារណជន វិនិយោគិនជាតិនិងអន្តរជាតិមកលើសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា។ ស.ហ.ក. បានបន្តពង្រឹងការវិភាគរបាយការណ៍ប្រតិបត្តិការ ការត្រួតពិនិត្យបុគ្គលរាយការណ៍ កិច្ចសហការជាមួយក្រសួង-ស្ថាប័ននិងភាគីពាក់ព័ន្ធ និងការអភិវឌ្ឍធនធានមនុស្ស លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានរួមចំណែកនៅក្នុងគំនិតផ្ដួចផ្ដើមសំខាន់ៗក្នុងការលើកកម្ពស់ហិរញ្ញប្បទានប្រកបដោយចីរភាព ដោយសារការប្រែប្រួលអាកាសធាតុបាននិងកំពុងបង្កហានិភ័យនៅគ្រប់ទីកន្លែងលើពិភពលោក ដែលក្នុងនោះកម្ពុជាក៏ជាប្រទេសមួយដែលរងផលប៉ះពាល់ខ្លាំងពីកត្តាអាកាសធាតុ ជាពិសេសចំពោះវិស័យកសិកម្ម។ ក្នុងទិសដៅនេះ ប្រព័ន្ធវត្ថុករសាស្ត្រស្ដីពីហិរញ្ញប្បទានប្រកបដោយចីរភាព និងផែនទីមគ្គុទេសក៍សម្រាប់ហិរញ្ញវត្ថុបៃតងនៅកម្ពុជាកំពុងត្រូវបានរៀបចំ ដែលឯកសារទាំងនេះនឹងក្លាយជាមូលដ្ឋានដ៏សំខាន់ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចបង្កើនហិរញ្ញប្បទាននិងការវិនិយោគបៃតងនាពេលខាងមុខ។

ម្យ៉ាងទៀត ស្របតាមស្មារតីក្នុងការចូលរួមកសាងសេដ្ឋកិច្ចផ្អែកលើពុទ្ធិ ធនាគារជាតិនៃកម្ពុជា តាមរយៈវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ បានបន្តអភិវឌ្ឍធនធានមនុស្សលើជំនាញបច្ចេកទេសធនាគារ ហើយក៏បានចាប់ផ្ដើមផ្ដល់ការសិក្សាថ្នាក់បរិញ្ញាបត្រផងដែរ។ ទន្ទឹមនេះ សារមន្ទីរព្រះស្រីល្បសានវឌ្ឍន៍ បានបន្តចូលរួមយ៉ាងសកម្មក្នុងការផ្ដល់ចំណេះដឹងហិរញ្ញវត្ថុនិងសេដ្ឋកិច្ចដល់សាធារណជន និងសិស្សានុ-សិស្ស ដោយនៅក្នុងឆមាសទី១នេះ មានភ្ញៀវចូលទស្សនាសរុបចំនួន ២៤.៣៣៨ រូប ដែលក្នុងនោះរួមមាន ទាំងភ្ញៀវជាតិ និងអន្តរជាតិ ហើយសិស្សានុសិស្ស មកពីបណ្ដាខេត្តនានា ក៏មានឱកាសចូលទស្សនាសារមន្ទីរផងដែរ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

សម្រាប់ទស្សនវិស័យរយៈពេលខ្លីនិងមធ្យមខាងមុខ សេដ្ឋកិច្ចពិភពលោកបន្តប្រឈមនឹងភាពមិនច្បាស់លាស់កាន់តែច្រើន ដោយសារការកើនឡើងជម្លោះប្រដាប់អាវុធ ក៏ដូចជាភាពតានតឹងភូមិសាស្ត្រនយោបាយនៅតាមតំបន់នានា បន្ថែមលើនិន្នាការគាំពារនិយម និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ គួបផ្សំនឹងបញ្ហាដក់សល់ពីវិបត្តិកូវីដ-១៩ ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍ។ កត្តាទាំងនេះអាចប៉ះពាល់ដល់សកម្មភាពពាណិជ្ជកម្មអន្តរជាតិ លំហូរវិនិយោគ និងខ្សែច្រវាក់ផ្គត់ផ្គង់សកល ដែលអាចធ្វើឱ្យសេដ្ឋកិច្ចពិភពលោកថយចុះលឿនជាងការរំពឹងទុក និងដាក់សម្ពាធលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិ ក៏ដូចជាបង្កើនហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។ នៅឆ្នាំ២០២៥ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា កំណើនសេដ្ឋកិច្ចពិភពលោកនឹងថមថយល្បឿនមកត្រឹម ២,៨% ពីអត្រា ៣,៣% នៅឆ្នាំ២០២៤ ហើយអាចកើនឡើង ៣% នៅឆ្នាំ២០២៦។

ស្ថិតក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យខាងក្រៅកាន់តែខ្លាំង ជាពិសេស ការអនុវត្តពន្ធគយបដិការរបស់សហរដ្ឋអាមេរិក ជម្លោះព្រំដែនកម្ពុជា-ថៃ និងភាពតានតឹងភូមិសាស្ត្រនយោបាយពិភពលោកនិងតំបន់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការនាំចេញ វិនិយោគផ្ទាល់បរទេស និងទេសចរណ៍នៅកម្ពុជា។ ទន្ទឹមនឹងហានិភ័យខាងក្រៅ សេដ្ឋកិច្ចកម្ពុជាក៏បន្តមានបញ្ហាប្រឈមខាងក្នុងមួយចំនួនផងដែរ រួមមាន ភាពទន់ខ្សោយនៃវិស័យសំណង់និងអចលនទ្រព្យ និងការងើបឡើងមិនទាន់ពេញលេញនៃវិស័យទេសចរណ៍ ក្នុងពេលដែលការធ្វើពិពិធកម្មសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះ ប្រព័ន្ធធនាគារបន្តប្រឈមនឹងភាពមិនច្បាស់លាស់នៃកំណើនសេដ្ឋកិច្ចផងដែរ ដែលអាចបន្តនាំឱ្យឥណទានមានកំណើនយឺត ហើយអនុបាតឥណទានមិនដំណើរការមានកម្រិតខ្ពស់។

អតិផរណាត្រូវបានព្យាករថាមានកម្រិតជាមធ្យម ២,៤% ដែលជាកម្រិតទាបអាចគ្រប់គ្រងបាន ដោយសារការផ្គត់ផ្គង់ក្នុងស្រុកបន្តមានភាពរឹងមាំ ហើយថ្លៃប្រេងឆៅពិភពលោកមាននិន្នាការថយចុះ។ នៅក្នុងប្រព័ន្ធធនាគារ ភាពធន់នៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនឹងបន្តបំពេញតួនាទីជាអន្តរការិយកម្មហិរញ្ញវត្ថុដ៏សំខាន់នៅក្នុងសេដ្ឋកិច្ច ស្របពេលដែលការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ នឹងបន្តចូលរួមលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចឌីជីថល។

ផ្អែកលើការព្យាករលើកំណើនតាមវិស័យ កំណើនសេដ្ឋកិច្ចនាឆ្នាំ២០២៥ ត្រូវបានរំពឹងថានឹងអាចសម្រេចបានក្នុងអត្រា ៥,២% មុននឹងកើនឡើងក្នុងអត្រា ៥,៣% នាឆ្នាំ២០២៦។ កំណើននេះត្រូវបានគាំទ្រជាចម្បងដោយការនាំចេញផលិតផលក្នុងវិស័យកម្មន្តសាល និងការបន្តងើបឡើងថែមទៀតនៃវិស័យទេសចរណ៍ ខណៈដែលវិស័យកសិកម្មបន្តមានកំណើនទាប។ ទោះយ៉ាងណា ការនាំចេញអាចថមថយល្បឿននៅក្នុងឆមាសទី២នេះ ជាពិសេសទៅកាន់សហរដ្ឋអាមេរិក ដែលមានចំណែកទីផ្សារធំជាងគេរហូតដល់ ៣៧,៥% ប្រសិនបើលោកប្រធានាធិបតី ដូណាល់ ត្រាំ រក្សាអត្រាពន្ធគយបដិការក្នុងកម្រិត ៣៦% លើទំនិញកម្ពុជា ដោយសារអត្រានេះមានកម្រិតខ្ពស់ជាងប្រទេសមួយចំនួនក្នុងតំបន់ដែលជាដៃគូប្រកួតប្រជែងសំខាន់ៗរបស់កម្ពុជា ដូចជា វៀតណាម ២០% និងឥណ្ឌូណេស៊ី ១៩%។ ការណ៍នេះអាចមានផលប៉ះពាល់ដល់វិស័យកាត់ដេរ និងប្រាក់ចំណូលរបស់កម្មករនិយោជិត និងអ្នកទទួលផលមួយចំនួនទៀត ដូចជា សមាជិកក្រុមគ្រួសារ និងអ្នកប្រកបអាជីវកម្មផ្សេងៗ។

ដោយឡែក ការវិវត្តនៃសភាពការណ៍ព្រំដែនកម្ពុជា-ថៃនាពេលថ្មីៗនេះ ដែលបានឈានទៅដល់ការផ្ទុះអាវុធក្នុងទ្រង់ទ្រាយធំ បានបន្ថែមសម្ពាធមកលើទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ និងអាចជះឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពសេដ្ឋកិច្ចនិងសង្គម ជាពិសេសវិស័យទេសចរណ៍ ពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាតែងតែចាត់ទុកសន្តិភាពគឺជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចប្រកបដោយថាមភាពនិងចីរភាព តាមរយៈការបង្កលក្ខណៈអំណោយផលដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានាឱ្យប្រព្រឹត្តទៅដោយពិលាស។ ក្នុងស្មារតីសន្តិភាពនិយមនេះ កម្ពុជាតែងតែប្រកាន់ជំហរចង់ដោះស្រាយបញ្ហាដោយសន្តិវិធី តាមរយៈយន្តការតុលាការយុត្តិធម៌អន្តរជាតិ ប៉ុន្តែភាគីថៃតែងបដិសេធយន្តការនេះ ព្រមទាំងបាន

បើកការវាយប្រហារមកលើកងទ័ពកម្ពុជា ដែលធ្វើឱ្យយើងគ្មានជម្រើសអ្វី ក្រៅពីការឆ្លើយតប ដោយកម្លាំងប្រដាប់អាវុធក្រោមសិទ្ធស្វ័យការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ។ ក្នុងកាលៈទេសៈនេះ ខ្ញុំសូមអំពាវនាវដល់មន្ត្រី-បុគ្គលិកយើងចូលរួមផ្តល់ការគាំទ្រ និងផ្តល់កម្លាំងចិត្តដល់កងទ័ពកម្ពុជានៅសមរភូមិជួរមុខ ដែលបាននិងកំពុងតស៊ូយ៉ាងអង់អាចក្លាហាន ដោយមិនខ្លាចពលីជីវិត ក្នុងបុព្វហេតុការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិមាតុភូមិយើងទាំងអស់គ្នា។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ដើម្បីជ្រាបពីសមិទ្ធផលលម្អិត ដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារសំខាន់ៗ ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតនាពេលបន្តិចទៀតនេះ។ ខ្ញុំសូមជូនពរឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងផ្លែផ្កា។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។**

**សូមអរគុណ!**